# ៥១- រឿង បុរសបាញ់ទង់

មាននិទានមួយដំណាលថា : នៅស្រុកមួយនោះ មានបុរស ២ នាក់ ម្នាក់ឈ្មោះថៅសោកែ ម្នាក់ទៀតឈ្មោះថៅពាលោ ។ ទៅរករៀនមន្តអាគមចេះសព្វគ្រប់ ហើយតែងរកឧបាយកលចំហូរយកទ្រព្យរបស់គេមកជារបស់ខ្លួន ។

ថ្ងៃមួយថៅសោកែចេញទៅបាញ់ទុងបានមួយ ។ ថៅពាលោគិតថា “ សោកែគាត់នឹងឲ្យសាច់ទុងអញស៊ីផងឬទេ ? បើគាត់មិនឲ្យសាច់ទុងអញស៊ីទេ អញនឹងរករឿងគាត់ឲ្យកើតជាក្ដីឡើងបានម្ដង ” ។ ឯថៅសោកែស្លអាំងសាច់ទុងរួចស្រេចក៏បរិភោគទៅ ពុំបានឲ្យទៅថៅពាលោឡើយ ។ ថៅពាលោក៏ប្ដឹងទៅថៅក្រម ឲ្យកោះថៅសោកែ យកទៅជំនុំជម្រះ ហើយថៅពាលោប្ដឹងថៅក្រមនោះថា “កាលឪពុកខ្ញុំព្រះបាទឈឺថ្កាត់នោះគាត់ផ្ដាំនឹងខ្ញុំព្រះបាទថា “បើគាត់ស្លាប់ទៅនឹងទៅយកកំណើតជាសត្វទុង ដោយជួរចំបួរមេបារៀង ៗ មកសឹងស្លាប់ទៅកើតជាទុងទាំងអស់ បើមានអ្នកណាមួយទៅបាញ់ទុង ឲ្យប្ដឹងថៅក្រមឲ្យចាប់យកទៅជំនុំពិចារណាលក់ពិន័យ តាមដោយនូវច្បាប់ស្លាប់គេ ឥឡូវនេះ ថៅសោកែសម្លាប់ឪពុកខ្ញុំស៊ី ហេតុនេះសូមព្រះបាទម្ចាស់កាត់សេចក្ដីឲ្យទានខ្ញុំព្រះបាទហោង ” ។

ឯថៅសោកែឆ្លើយដោះសារថា “ឪពុកម្ដាយខ្ញុំប្រាប់រៀង ៗមកថា “ មេបាជីដូនជីតាឪពុកម្ដាយ អម្បាលដែលស្លាប់ទៅសឹងយកកំណើតជាត្រី ហើយផ្ដាំថា បើមានសារពើសត្វអ្វីទៅសម្លាប់សត្វត្រីស៊ី ឲ្យខ្ញុំប្របាទបាញ់សម្លាប់សត្វអស់នោះស៊ីវិញ បើសត្វអស់នោះមានកូនចៅផៅពង្សនៅជាមនុស្ស ឲ្យប្ដឹងថៅក្រមឲ្យចាប់យកមកជំនុំជម្រះលក់ពិន័យកូនចៅផៅពង្សអស់នោះ ឥឡូវនេះ ហ្វូងទង់នាំគ្នាទៅប្លន់ចាប់ត្រីជាជីដូនជីតាឪពុកម្ដាយខ្ញុំប្របាទស៊ី ទើបខ្ញុំប្របាទបាញ់ទុងអស់នោះ, ឥឡូវបើថៅពាលោថាទុងនោះជាឪពុកគេដូច្នេះ សូមអស់លោកជាថៅក្រមជំនុំជម្រះ ពិចារណាសេចក្ដីនេះឲ្យទានខ្ញុំប្របាទចុះ ” ។

ថៅក្រមជំនុំពិចារណាសេចក្ដីនេះមិនដាច់ស្រេច ទើបនាំថៅទាំង ២ នាក់ ឡើងទៅក្រាបបង្គំទូលព្រះមហាក្សត្រតាមដំណើរសេចក្ដីនោះសព្វគ្រប់ប្រការ ។ ថៅពាលោឃើញថាក្ដីរបស់ខ្លួនចាញ់ប្រៀបក្ដីរបស់ថៅសោកែ ទើបនិយាយដោះសាខ្លួនថា “ ថៅសោកែពុំបានបាញ់ទុងនៅអាយឡើយបាញ់ទុងពីនាយទេ ខ្ញុំព្រះបាទអម្ចាស់ប្រកាន់ត្រង់នេះឯង ” ។

ព្រះមហាក្សត្រ មានព្រះបន្ទូលដណ្ដឹងសួរទៅថៅពាលោថា “ ឯទុងឪពុកថៅនៅឯអាយស៊ីអ្វី ស៊ីក្ដាមខ្យងឬស៊ីត្រី ? ” ។ ថៅពាលោក្រាបទូលថា “ ស៊ីត្រី ” ។ ព្រះមហាក្សត្រមានព្រះបន្ទូលថា “ បើដូច្នេះទុងជាឪពុកឯងចាប់ត្រីជាឪពុកថៅសោកែស៊ី ដូចពាក្យថៅសោកែមែន ” ហើយទ្រង់បង្គាប់ឲ្យថៅពាលោទៅជាខ្ញុំថៅសោកែ ។ ថៅទាំង ២ ក៏សុខចិត្ត